សង្ខេបសម្រាប់
គោលនយោបាយ
ឆ្នាំ២០២៣ លេខ០៦

# ការបង្កើនលទ្ធភាពទទួលបាន សេវាថែទាំកុមារតូចដែលមានគុណភាពល្អ និងតម្លៃសមរម្យនៅកម្ពុជា៖ យន្តការឈ្នះ-ឈ្នះ សម្រាប់កុមារតូច និងស្ត្រីកម្ពុជា

## តើហេតុអ្វីបានជាការថែទាំកុមារតូចមានសារៈសំខាន់?

**កុមារគ្រប់រូបមានសិទ្ធ ក្នុងការទទួលបានការថែទាំដែលមានគុណភាព។** ការវិនិយោគលើការថែទាំកុមារតូច ទាំងពីសំណាក់រដ្ឋាភិបាល និងវិស័យឯកជន ត្រូវបានទទួលស្គាល់ជាសាកលថា វាជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍមូលធនមនុស្ស និងកំណើនសេដ្ឋកិច្ច។ ដោយឡែក ធនាគារពិភពលោកបានកំណត់មូលធនមនុស្សជាបីផ្នែកធំៗគឺ៖ ចំណេះដឹង ជំនាញ និងសុខភាព (The World Bank Group, 2020)។ រយៈពេលបីឆ្នាំដំបូងនៃជីវិតរបស់កុមារ គឺជាដំណាក់កាលសំខាន់ក្នុងការលូតលាស់ខួរក្បាល និងសុខភាពរយៈពេលវែងរបស់ពួកគេ។ ដូច្នេះហើយ ការទទួលបាននូវការថែទាំដែលមានគុណភាពល្អ សេវាសុខភាព និងកម្មវិធីអប់រំទាំងនៅក្នុងផ្ទះ និងក្រៅផ្ទះ ក៏ដូចជាអាហារូបត្ថម្ភគ្រប់គ្រាន់ ពិតជាមានអត្ថប្រយោជន៍សម្រាប់កុមារតូចទូទាំងសាកលលោក។ ហើយការណ៍ដែលកុមារមិនអាចទទួលបាននូវការថែទាំដែលមានគុណភាពល្អបាន អាចបង្កឱ្យមានបញ្ហាគន្លឹះពីរធំៗគឺ៖ កង្វះអាហារូបត្ថម្ភ និងការចូលរួមតិចតួចរបស់ស្ត្រីនៅក្នុងទីផ្សារការងារ។



**កង្វះអាហារូបត្ថម្ភ គឺជាបន្ទុកដល់សេដ្ឋកិច្ចប្រទេស៖** កង្វះអាហារូបត្ថម្ភសម្រាប់កុមារ អាចបង្កឱ្យមានហានិភ័យដល់ជីវិត ព្រមទាំងភាពយឺតយ៉ាវ ក្នុងការលូតលាស់ខួរក្បាល និងកម្សោយជំនាញចលនារបស់កុមារ (World Vision 2018; Sethi et al. n.d.; Cavagnari et al. 2023)។ ជម្ងឺកុមារក្រិសក្រិនសម្រាប់កុមារក្រោមអាយុប្រាំឆ្នាំនៅតែមានអត្រាខ្ពស់ ដោយកុមារម្នាក់នៅក្នុងចំណោមកុមារ ៥នាក់ មានជំងឺនេះ បើតាមតួលេខនៅក្នុងឆ្នាំ២០២១។ ក្រៅពីភាពក្រីក្រ ការផ្ដល់អាហារដល់កុមារតូចដោយមិនត្រឹមត្រូវ ដោយសារតែកង្វះចំណេះដឹងទៅលើអាហារូបត្ថម្ភ និងការថែទាំនិងអភិវឌ្ឍន៍កុមារតូចក៏ជះឥទ្ធិពលទៅលើកង្វះអាហារូបត្ថម្ភសម្រាប់កុមារតូចផងដែរ។

**ការចូលរួមតិចក្នុងទីផ្សារការងារ៖** នៅពេលដែលកុមារមិនអាចទទួលបាននូវសេវាថែទាំកុមារដែលមានគុណភាព វាក៏បានកម្រិតនូវលទ្ធភាពរបស់ស្ត្រី ក្នុងការចូលក្នុងកម្លាំងពលកម្មផងដែរ។ ដោយសារការថែទាំកុមារតូច គឺត្រូវបានគេយល់ឃើញថា វាជាបន្ទុករបស់ស្ត្រី ជាពិសេសស្ត្រីជាម្ដាយ។ ដោយមូលហេតុនេះ មានស្ត្រីជាច្រើនដែលមិនបានចូលរួមក្នុងកម្លាំងពលកម្ម ខណៈដែលស្ត្រីជាម្ដាយខ្លះទៀត ត្រូវបោះបង់ការងាររបស់ពួកគេក្រោយពេលសម្រាលកូន ហើយពួកគេមិនអាចត្រឡប់ទៅធ្វើការងារវិញបាន។ ស្ត្រីជាម្ដាយម្នាក់ដែលបានបោះបង់ការងារ ក្រោយពេលដែលទុកកូនតូចរបស់គាត់ ឱ្យម្ដាយ

រៀបរៀងដោយ ជ្រា សែសុគន្ធីដេត អ្នកស្រាវជ្រាវ មជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន CDRI។
សូមយោងអត្ថបទនេះថា៖ Chrea Sesokunthideth. 2023. *Improving Access to Quality and Affordable Childcare Services: A win-win for Cambodian Children and Women.* Policy Brief 2023 No. 06. Phnom Penh: CDRI.

សង្ខេបគោលនយោបាយនេះ ផ្អែកលើរបាយការណ៍គោលនយោបាយរបស់ CDRI ស្ដីពីការផ្គត់ផ្គង់ និងតម្រូវការសម្រាប់សេវាថែទាំកុមារដែលអាចដំណើរការបាន និងតម្លៃសមរម្យនៅកម្ពុជា។

មើលថៃជំនួសមួយរយៈពេល បាននិយាយថា "នៅពេលដែលម្ដាយខ្ញុំមើលថៅ គាត់តែងតែឱ្យកូនខ្ញុំញ៉ាំតាមតែចិត្តរបស់វា។ ហើយកូនខ្ញុំក៏ឈឺ អស់រយៈពេលជិតពីរអាទិត្យក្នុងមួយខែ ដោយសារតែការញ៉ាំចំណីអាហារដែលមិនជួយដល់សុខភាព។ ដូច្នេះហើយ ទើបខ្ញុំសម្រេចចិត្តឈប់ពីការងារ មកលើថៃកូនតូចរបស់ខ្ញុំពេញម៉ោងតែម្ដង"។ ម៉្យាងទៀត នៅពេលដែលស្ត្រីជាម្ដាយសម្រេចចិត្តថានឹងទៅធ្វើការងារ ពួកគេតែងជ្រើសយកការងារដែលពេលវេលា អាចមានភាពបត់បែនបាន ដែលការងារនោះភាគច្រើន គឺស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬការរកស៊ីផ្ទាល់ខ្លួន ដែលវាមានផលប៉ះពាល់ដល់ចំណូលរបស់ពួកគាត់ផងដែរ។ លើសពីនេះទៅទៀត ម្ដាយដែលកំពុងធ្វើការងារក៏ត្រូវទុកកូនតូចឱ្យនៅជាមួយជីដូនជីតា ឬអ្នកដទៃផ្សេងទៀត ដោយផ្ដល់ការប៉ះប៉ូវជាទឹកប្រាក់ ឬវត្ថុផ្សេងៗ សម្រាប់ការជួយមើលកូនរបស់ពួកគេ (Chhin, 2022; UN Women, 2020)។

**ការផ្គត់ផ្គង់ សេវាថៃទាំកុមារផ្លូវការនៅកម្ពុជា នៅមានកម្រិតនៅឡើយ៖** សេវាថៃទាំកុមារតូចឯកជនមានចំនួនតិចតួច ហើយមានតម្លៃខ្ពស់សម្រាប់គ្រួសារមួយភាគធំ ជាពិសេសគ្រួសារដែលមានចំណូលទាប។ បច្ចុប្បន្ននេះ មានគ្រួសារមួយភាគតូចប៉ុណ្ណោះ ដែលអាចប្រើប្រាស់សេវាថៃទាំកុមារផ្លូវការបាន ដោយសារតែនៅមានកង្វះខាតច្រើនទាំងនៅក្នុងផ្នែកផ្គត់ផ្គង់ និងតម្រូវការការថៃទាំកុមារតូច។ សេវាថៃទាំកុមារតូចក៏មានកម្រិតតិចតួច ជាពិសេសនៅតំបន់ជនបទ។ ដោយឡែកបើទោះជាមានសេវាថៃទាំកុមារតូចក៏ដោយ ក៏សេវាទាំងនេះមានតម្លៃខ្ពស់ ហើយស្តង់ដារគុណភាពហាក់មិនឆ្លើយតបទៅនឹងការរំពឹងទុករបស់ឪពុកម្ដាយនៅឡើយទេ។ ម៉្យាងទៀត កង្វះការយល់ដឹងអំពី អត្ថប្រយោជន៍នៃសេវាថៃទាំកុមារតូចផ្លូវការ សម្រាប់ការអភិវឌ្ឍកុមារតូច និងការបន្តកើតមាននូវផ្នត់គំនិតសង្គមជុំវិញការថៃទាំកូនតូច និងការធ្វើការងាររបស់ស្ត្រី បានធ្វើឱ្យមានល្បឿននៃការប្រើប្រាស់សេវាថៃទាំកុមារ នៅមានកម្រិតផងដែរ។

**ស្តង់ដារការថៃទាំកុមារ នៅតែជាក្តីព្រួយបារម្ភមួយ៖** យោងតាមការសិក្សាស្តីពីការផ្គត់ផ្គង់ និងតម្រូវការនៃភាពងាយស្រួល និងលទ្ធភាពទទួលយកបាននូវសេវាថៃទាំកុមារនៅកម្ពុជា[1] បានបង្ហាញថា ម្ដាយជាច្រើនបានបង្ហាញអំពី ការព្រួយបារម្ភពីផលប៉ះពាល់អវិជ្ជមានរបស់អ្នកថៃទាំ ដែលមិនមានវិជ្ជាជីវៈទៅលើការលូតលាស់ និងសុខុមាលភាពរបស់កុមារ។ នេះជាភ័ស្តុតាងមួយនាំឱ្យមានកង្វះអាហារូបត្ថម្ភ កង្វះការចូលរួមក្នុងសង្គម បញ្ហាសុខភាពនិងសុវត្ថិភាព។ ម្ដាយទាំងនេះរំពឹងថា អ្នកថៃទាំកុមារនឹងមានការយកចិត្តទុកដាក់ ក្នុងការមើលថៃ ប្រើប្រាស់ភាសាសមរម្យជាមួយកុមារ និងមានទំនាក់ទំនងល្អជាមួយនឹងមាតាបិតារបស់កុមារ។ ពួកគាត់ក៏រំពឹងផងដែរ ទៅលើចំណុចមួយចំនួនទៀតដូចជា៖ សមាមាត្រផលធៀបរវាងចំនួនអ្នកថៃទាំកុមារ និងចំនួនកុមារតូច ការផ្ដល់ចំណីអាហារ និងអាហារសម្រន់ដែលល្អចំពោះសុខភាព ការផ្ដល់នូវសុវត្ថិភាព ការផ្ដល់សេវា





១ របាយការណ៍ស្រាវជ្រាវ៖ ការផ្គត់ផ្គង់ និងតម្រូវការសេវាថៃទាំកុមារដែលអាចដំណើរការបាន និងតម្លៃសមរម្យនៅកម្ពុជា ឆ្នាំ២០២៣



1 Research report: Supply of and demand for accessible and affordable childcare services in Cambodia 2023




ថែទាំសុខភាព កន្លែងក្មេងលេង និងឧបករណ៍ក្មេងលេង កន្លែងសម្រាប់កុមារគេង និងកម្មវិធីថែទាំ/សិក្សាល្អៗ (ឧទាហរណ៍ ការបង្រៀនភាសា ការអប់រំអាកប្បកិរិយា និងការផ្តល់ការកម្សាន្ត)។ ដោយឡែក អ្នកថែទាំដែលជាម្តាយ ឬជីដូន/ជីតាភាគច្រើន តែងតែអនុញ្ញាតឱ្យកុមារតូច មើលទូរស័ព្ទដៃ (smartphones) ជាពិសេសនៅពេលដែលកុមារមានអាយុចាប់ពីមួយឆ្នាំឡើងទៅ ទោះបីជាពួកគាត់បានដឹងអំពីផលប៉ះពាល់អវិជ្ជមានពីការធ្វើបែបនេះក៏ដោយ។

**ស្ត្រីមានបំណងចង់ធ្វើការងារ៖** ការសិក្សាមួយបានបង្ហាញថា អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្ត្រី មានរហូតទៅដល់ ៨០% ដែលជាអត្រាមួយខ្ពស់ នៅក្នុងតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក (Gavalyugova et al., 2019)។ ស្ត្រីជាម្តាយ ទាំងដែលកំពុងមានការងារធ្វើ និងមិនមានការងារធ្វើ មានបំណងចង់មានការងារធ្វើ ឬត្រឡប់ទៅធ្វើការងារវិញ ហើយម្តាយទាំងនេះក៏មានចំណាប់អារម្មណ៍ខ្ពស់ ក្នុងការប្រើប្រាស់សេវាថែទាំកុមារតូចដែលងាយស្រួលក្នុងការប្រើប្រាស់ មានតម្លៃសមរម្យ និងអាចជឿទុកចិត្តបាន។

**កម្លាំងពលកម្មស្ត្រី ជួយដល់សេដ្ឋកិច្ចជាតិ៖** សេវាថែទាំកុមារតូចដែលមានគុណភាពល្អ និងងាយស្រួលក្នុងការប្រើប្រាស់ អាចជួយជម្រុញការចូលរួមទៅក្នុងការងាររបស់ស្ត្រី ព្រមទាំងកាត់បន្ថយការអវត្តមានពីការងារ និងបង្កើនផលិតភាពរបស់ពួកគេផងដែរ ខណៈពេលដែលកុមារក៏ទទួលបានការអភិវឌ្ឍពេញលេញ។ អត្ថប្រយោជន៍ទាំងនេះ ក៏ជម្រុញដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងរយៈពេលវែងផងដែរ។

## គម្លាតនៅក្នុងគោលនយោបាយ ការវិនិយោគ និងតម្រូវការរបស់និយោជក។

ប្រទេសកម្ពុជាមានឯកសារ ឬបទដ្ឋានគតិយុត្តិមួយចំនួនដែលពាក់ព័ន្ធនឹងការថែទាំកុមារតូចដូចជា ច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការអប់រំ និងច្បាប់ស្តីពីការងារ។ ប៉ុន្តែ តម្រូវការសេវាថែទាំកុមារនេះ មិនត្រូវបានឆ្លើយតបដោយពេញលេញនៅឡើយ។ ដោយសារតែកង្វះខាត អ្នកផ្តល់សេវាថែទាំកុមារតូចដែលងាយស្រួលក្នុងការប្រើប្រាស់ និងមានតម្លៃសមរម្យ និងការវិនិយោគរបស់រដ្ឋនៅមានកម្រិតនៅឡើយ។ មួយវិញទៀត ទារកដ្ឋាន នៅមិនទាន់បានបំពាក់ឧបករណ៍សម្ភារគ្រប់គ្រាន់នៅឡើយ។ ស្រដៀងគ្នានេះដែរ ទោះបីជាមាត្រា១៨៦ នៃច្បាប់ស្តីពីការងារបានចែងថា និយោជកដែលមានបុគ្គលិកជាស្ត្រីចាប់ពី ១០០នាក់ឡើង ត្រូវបង្កើតទារកដ្ឋាននៅក្នុងកន្លែងការងារ ឬទទួលខុសត្រូវដោយបង់ថ្លៃសេវាថែទាំកុមារតូច ដល់បុគ្គលិកស្ត្រីដែលមានកូនតូចអាយុចាប់ពី ១៨ ទៅ ៣៦ខែ។ ប៉ុន្តែ ការអនុវត្តនៅមិនទាន់បានរឹតបន្តឹងនៅឡើយទេ។

ក្រៅពីនេះ ក៏នៅមានកង្វះខាតសេចក្តីណែនាំក្នុងការបង្កើតទារកដ្ឋានដែលងាយស្រួលក្នុងការប្រើប្រាស់ និងមានគុណភាពល្អ ក៏ដូចជាកម្រិតតម្លៃដែលនិយោជកត្រូវបង់ សម្រាប់សេវាថែទាំកុមារតូចរបស់បុគ្គលិកខ្លួនផងដែរ។ ជាមួយគ្នានេះដែរ ខណៈដែលម្តាយទទួលបាននូវ ការសម្រាកលំហែមាតុភាពរយៈពេលតែបីខែក្រោយសម្រាល ស្ត្រីដែលមានកូនតូចអាយុពី ៣ ទៅ ១៨ខែ ត្រូវបង្ខំចិត្តឈប់ពីការងារដើម្បីមើលថែកូនតូច។

**តម្រូវការថែទាំកុមារកំពុងតែកើនឡើង៖** ស្ត្រីជួបប្រទះនូវរបាំងដែលរារាំងពួកគាត់ មិនឱ្យចូលរួមក្នុងទីផ្សារការងារ ឬឱកាសក្នុងការរកចំណូលផ្សេងៗបាន។ តែការចូលរួមរបស់ស្ត្រីមានសារៈសំខាន់ សម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជាទាំងបច្ចុប្បន្ន និងនាពេលអនាគត។ ដូច្នេះ សេវាថែទាំកុមារតូចដែលងាយស្រួលប្រើប្រាស់ មានតម្លៃសមរម្យ និងមានគុណភាពល្អ គឺជាគន្លឹះសំខាន់ក្នុងការសម្រេចបាននូវគោលដៅនេះ។

**អនុក្រឹត្យស្តីពីការថែទាំកុមារ៖** ក្នុងការឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ទៅលើការអភិវឌ្ឍកុមារ និងការចូលរួមផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី អនុក្រឹត្យជាក់លាក់ស្តីពីការថែទាំកុមារតូចសម្រាប់កុមារដែលមានអាយុចាប់ពី ៣ខែ ទៅដល់ ៣ឆ្នាំ គួរត្រូវបានបង្កើតឡើង និងអនុម័ត។ អនុក្រឹត្យ

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

ស្តីពីការថែទាំកុមារតូច គួរតែត្រូវមានការបំពេញចន្លោះប្រហោងផ្នែកគោលនយោបាយ និងហិរញ្ញប្បទាន ដើម្បីធានាបាននូវការអប់រំសម្រាប់ទាំងអស់គ្នា ហើយគ្មាននរណាម្នាក់ត្រូវបានមើលរំលងឡើយ។ អនុក្រឹត្យត្រូវតែផ្តល់នូវការណែនាំទៅដល់រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និយោជក អ្នកផ្តល់សេវាថែទាំកុមារតូច និងសហគមន៍ ដោយកំណត់យ៉ាងច្បាស់នូវតួនាទី និងការទទួលខុសត្រូវរួមរបស់ពួកគេទៅលើការបង្កើត និងការវិនិយោគទៅលើសេវាថែទាំកុមារតូច។

**ការវិនិយោគ និងនិរន្តរភាព៖** ដោយភ្ជាប់ជាមួយគោលនយោបាយក្នុងការថែទាំកុមារ ការវិនិយោគពីវិស័យរដ្ឋ គឺជាគន្លឹះនៃការបង្កើតឱ្យមានសេវាថែទាំកុមារតូច ដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់ មានតម្លៃសមរម្យ គុណភាពល្អ និងមាននិរន្តរភាព។ និយោជកត្រូវតែអនុលោមទៅតាមច្បាប់។ តម្លៃក៏ជាបញ្ហាសំខាន់ សម្រាប់សេវាថែទាំកុមារតូចដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់ និងនិរន្តរភាពនៃសេវា ហើយវាត្រូវតែអនុវត្តដោយស្មើភាពគ្នា សម្រាប់ការប្រើប្រាស់ ដើម្បីធានានូវការប្រើប្រាស់សេវាថែទាំកុមារតូច ប្រកបដោយបរិយាបន្នទូទាំងប្រទេស។

**ការយល់ដឹងជាសាធារណៈអំពីការថែទាំកុមារតូច៖** ការយល់ដឹងជាសាធារណៈក្នុងចំណោមឪពុកម្តាយ ជីដូនជីតា និងសមាជិកគ្រួសារផ្សេងទៀត មានសារៈសំខាន់ណាស់។ វិធីសាស្ត្រជាច្រើន ត្រូវបានទាមទារ ដើម្បីធានាការយល់ដឹងរបស់សាធារណជនអំពី សារៈសំខាន់នៃការថែទាំកុមារប្រកបដោយគុណភាពសម្រាប់កុមារដែលមានអាយុពី ៣ខែ ដល់ ៣ឆ្នាំ។ នេះរាប់បញ្ចូលទាំងការរៀនពីវ័យកុមារភាព ជំនាញសង្គម និងអន្តរបុគ្គល ជំនាញវិភាគ អាហារូបត្ថម្ភ និងការត្រួតពិនិត្យសុខភាពកុមារ។

**សេវាថែទាំកុមារផ្អែកលើតម្រូវការ និងមានតម្លៃសមរម្យ៖** មិនមានអ្វីមួយ ដែលអាចបំពេញគ្រប់តម្រូវការទាំងអស់ឡើយ។ ការសិក្សាស្រាវជ្រាវសូមណែនាំឱ្យមានគំរូ ឬម៉ូឌែលសេវាថែទាំកុមារតូចខុសៗគ្នាសម្រាប់កុមារ និងឪពុកម្តាយផ្សេងៗគ្នា។ វាមានសារៈសំខាន់ណាស់ក្នុងការធានាថា សេវាថែទាំកុមារ គឺផ្អែកលើតម្រូវការ និងមានតម្លៃសមរម្យសម្រាប់ទាំងអស់គ្នា។

**ការគ្រប់គ្រងទិន្នន័យការថែទាំកុមារតូច និងការធ្វើអធិការកិច្ច៖** បង្កើតប្រព័ន្ធទិន្នន័យថែទាំកុមារតូច ដោយការកត់ត្រានូវស្ថិតិនៃអ្នកផ្តល់សេវាថែទាំកុមារ ការចុះបញ្ជីពាណិជ្ជកម្ម និងការចុះឈ្មោះកុមារ ដើម្បីជួយដល់ការកែលម្អសេវាថែទាំកុមារនៅកម្ពុជា។ ទិន្នន័យថែទាំកុមារ មានសារៈសំខាន់ខ្លាំងណាស់ក្នុងការជូនដំណឹងដល់រដ្ឋាភិបាល និយោជក ដៃគូអភិវឌ្ឍន៍ និងឪពុកម្តាយអំពីការវិនិយោគ និងការទទួលផលត្រឡប់មកវិញពីការថែទាំកុមារ។

## ឯកសារយោង


Cavagnari, Brian M., Darío Javier Guerrero-Vaca, Tannia Valeria Carpio-Arias, Samuel Duran-Aguero, Andrés Fernando Vinueza-Veloz, María Paulina Robalino-Valdivieso, Yadira Alejandra Morejón-Terán, and María Fernanda Vinueza-Veloz. "The double burden of malnutrition and gross motor development in infants: A cross-sectional study." *Clinical Nutrition* (2023).

Chhin, M. 2022. *Senior Citizens Take on Larger Childcare Role for Grandkids.* Phnom Penh Post, Cambodia https://www.phnompenhpost.com/national-post-depth/senior-citizens-take-larger-child-care-role-grandkids (accessed: 09.02.2024)

Gavalyugova, Dimitria, and Wendy Cunningham. *"Gender analysis of the Cambodian labor market."* (2020)

Sethi, Pranshul, Aradhana Prajapati, Tejesvi Mishra, Tanu Chaudhary, and Sumit Kumar. "Effects of Malnutrition on Brain Development." In *Nutrition and Psychiatric Disorders*, pp. 75-88. Singapore: Springer Nature Singapore, 2022

Women, U. N., *"Unlocking the lockdown: The gendered effects of COVID-19 on achieving the SDGS in Asia and the Pacific."* Retrieved on May 7 (2020): 2021.

World Vision International 2018. *Malnutrition Ending in Cambodia Is Possible.* 2018 Cambodia Policy Brief on Nutrition. https://www.wvi.org/cambodia/publication/ending-malnutrition-cambodia-possible